**Pélerinage en Inde** (Les noms des sites historiques sont en caractère gras)






# ដំណើរ ធម្មយាត្រាទៅប្រទេសឥណ្ឌា និង ប្រទេស នេប៉ាល់

ដោយ អាន ត្យ គីម

កាលពីថ្ងៃទីម្ភៃពីរខែវិច្ឆិកាឆ្នាំពីរពាន់ប្រាំមួយ រហូតដល់ថ្ងៃទីដប់បីខែធ្នូឆ្នាំពីរពាន់ប្រាំមួយ ពុទ្ធបរិស័ទវត្តពោធិវង្សយើងខ្លះ រួមជាមួយនឹងបងប្អូនខ្មែរយើងនៅប្រទេសបារាំង និងនៅប្រទេសកម្ពុជា រួមទាំងអស់ចំនួនសែសិបនាក់ បានធ្វើដំណើរធម្មយាត្រាទៅប្រទេសឥណ្ឌា និង ប្រទេស នេប៉ាល់ ដោយមានព្រះភិក្ខុចិត្តការោ ទូច សារិទ្ធ ជាមគ្គុទ្ទេសក៍ ។ ធម្មយាត្រានេះ មានគោលបំណង ចង់ទៅគោរពដល់ទីកន្លែង ជាពុទ្ធបូជនីយស្ថាន ដែលទាក់ទងនឹងជីវប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធ ពោលគឺ
យើងបានទៅនមស្សការ គោរពបូជា :

១- កន្លែងព្រះអង្គទ្រង់ប្រសូតិនៅ**ឧទ្យានលុម្ពិនី**

២- កន្លែងព្រះអង្គទ្រង់ត្រាស់ដឹង នៅ**ពុទ្ធគយា**

៣- កន្លែងព្រះអង្គទ្រង់**សម្តែងធម្មចក្រ** ជាលើកដំបូង ប្រោសបញ្ចវគ្គីយភិក្ខុ

៤- កន្លែងព្រះពុទ្ធអង្គទ្រង់**ចូលព្រះនិព្វាន** ។

ក្រុមធម្មយាត្រាយើង បានចេញដំណើរពីប្រទេសបារាំង នៅថ្ងៃទីម្ភៃពីរខែវិច្ឆិកាឆ្នាំពីរពាន់ប្រាំមួយ ចំណែកក្រុមធម្មយាត្រា ប្រទេសកម្ពុជាចេញដំណើរមុនយើងមួយថ្ងៃ ហើយបានទៅជួបជុំគ្នាទាំងអស់ នៅវត្តខ្មែរ ញូវដែលី ។ ចំណោមអ្នកអញ្ជើញពីប្រទេសខ្មែរ មានចុងភៅជាំស្វ និងមានអ្នកបច្ចេកទេស ថតរូបនិងវីដេអូឌីវីឌី ។
ម៉ោងនៅឯប្រទេសឥណ្ឌា លឿនជាងម៉ោងនៅប្រទេសបារាំង ចំនួនបួនម៉ោងកន្លះ យន្តហោះយើងបានចុះចត នៅអាកាសយានដ្ឋានអន្តរជាតិញូវ ដែលី នៅម៉ោងម្ភៃបីដប់ប្រាំនាទីម៉ោងប្រទេសបារាំង ត្រូវនឹងម៉ោងបីសែសិបប្រាំនាទីព្រឹកប្រទេសឥណ្ឌា នៅចំណតយន្តហោះញូវ ដែលី ក្រុមធម្មយាត្រាយើងបានទទួល ស្វាគមន៍ពីព្រះសង្ឃខ្មែរ នៅវត្តញូវ ដែលី ដែលមានកន្លែងទទួលឲ្យស្នាក់នៅ ។

១ - ក្រុង ដែល្លី (Delhi)

គណធម្មយាត្រា បានទស្សនាឧទ្យានពុទ្ធជយន្តិ
មានទំហំធំច្រើនហិកតា បានបង្កើតឡើងដើម្បីបង្ហាញដល់ពិភពលោក
ថាព្រះពុទ្ធសាសនាបានកើតឡើង នៅឯប្រទេសឥណ្ឌា ។ ក្រុង ដែល្លី
នេះ នាសម័យព្រះពុទ្ធ មានឈ្មោះថា ដែនកុរុ បានឮមកថាអ្នកស្រុក
ដែនកុរុទាំងឡាយសុទ្ធតែ ជាអ្នកកាន់សីលប្រាំ និង បដិបត្តិនូវ
សតិបដ្ឋាន ។ រហូតមកដល់សព្វថ្ងៃនេះ គេថាជន ជាតិឥណ្ឌាពូកែ
ខន្តី ជេរមិនឈឺ ហើយ មិនសូវវ៉ៃតប់គ្នាទេ ។



ឧទ្យានពុទ្ធជយន្តិ
Jardin bouddhique à Delhi

២- ក្រុងសាវត្ថី (Sravasti)

ធម្មយាត្រា ទាំងសែសិបនាក់ បន្ទាប់ពីបានសម្រាកនៅវត្តខ្មែរញូវ
ដែល្លី មួយយប់ មក នៅម៉ោងបីព្រឹកបាន បន្តដំណើរឆ្ពោះទៅ
កាន់ក្រុងសាវត្ថី មានចម្ងាយ ប្រាំបួនរយគីឡូម៉ែត្រ យើងបានទៅដល់
វត្តខ្មែរ នៃក្រុងសាវត្ថីនៅម៉ោងម្ភៃមួយយប់ ។
សម័យពុទ្ធកាល នៅក្រុងសាវត្ថី ព្រះរាជា ព្រះបាទបសេនទិកោសល
ជាសាសនូបត្ថម្ភ យើងបានទៅទស្សនាវត្តជេតពន
បានឃើញព្រះធម្មសភា គន្ធកុដិ កុដិព្រះសារីបុត្រ កុដិព្រះមោគ្គល្លាន
កុដិព្រះអង្គុលិមាល៍ កុដិព្រះអានន្ទ ស្រះទឹក អារាមរបស់ភិក្ខុនី
ដើមពោធិ៍ព្រះអានន្ទ កុដិព្រះពុទ្ធគង់នារដូវក្តៅ កុដិព្រះពុទ្ធគង់នារដូវ
ត្រជាក់ធម្មសាលា អាសនៈព្រះពុទ្ធគង់សម្តែងធម៌ប្រោស
នាងបដាចារ និងផ្ចាញ់នាងចិញ្ចាមាណវិកា ។
យើងបានធ្វើដំណើរចាកវត្តជេតពនដើម្បីទៅទស្សនាព្រះរាជវាំងព្រះ
បាទបសេន ទិកោសល និងឃ្លាំងមាសប្រាក់នៃអនាថបិណ្ឌិកសេដ្ឋី
ឃ្លាំងប្រាក់បិតាអង្គុលិមាល៍ ។ ជិតវត្តជេតពន
មានកន្លែងផែនដីស្រូបភិក្ខុទេវទត្តនិងនាងចិញ្ចា ភ្ជុំយមកបាដិហារ្យ
ជាកន្លែងព្រះពុទ្ធអង្គទ្រង់សម្តែងបាដិហារ្យ ផ្ចាញ់ពួកនិគន្ថនាដបុត្រ
ដែលប្រឆាំងព្រះអង្គ រួចហើយទ្រង់និមន្តទៅកាន់ឋានតាវត្តិង្ស
ដើម្បីប្រោសពុទ្ធមាតា ។



វត្តជេតពន
Vestige de la pagode Jetaban



វត្តខ្មែរ នៃក្រុងសាវត្ថី
Pagode khmer à Sravasti

45

## ៣ - ឧទ្យានលុម្ពិនី ( Lumbini )



យើងធ្វើដំណើរចាកក្រុងសាវត្ថី ឆ្ពោះទៅឧទ្យានលុម្ពិនី ជាកន្លែងព្រះអង្គទ្រង់ប្រសូត សព្វថ្ងៃនេះមានវត្តពុទ្ធសាសនាជាច្រើន ជារបស់ប្រទេសអាស៊ី ដូចជា: ថៃ វៀតណាម ខ្មែរ ឥណ្ឌា ភូមា ស៊ិរីលង្កា ជប៉ុន ចិន ជាដើម ។ វត្តទាំងនោះ សង់នៅជុំគ្នា ហើយមានផ្ទៃដីធំ ជាអំណោយរដ្ឋាភិបាលឥណ្ឌានិងនេប៉ាល់ ចែកឲ្យប្រទេសនិមួយ ។ ជាទានមរតក។

កន្លែងព្រះអង្គទ្រង់ប្រសូត

វត្តខ្មែរនៅ លុម្ពិនី



ចំពោះវត្តខ្មែរនៅទីនោះ មានផ្ទៃដីបួនជ្រុងទ្រវែងរាបស្មើ មានកំពែងឥដ្ឋស៊ីម៉ង់ត៍ព័ទ្ធជុំវិញ ទើបតែសង់បានអាគារមួយខ្នងប៉ុណ្ណោះ ជាកន្លែង ស្នាក់នៅនៃពុទ្ធបរិស័ទ ដែលអញ្ជើញធ្វើធម្មយាត្រាទៅដល់ទីនោះ ។ សូមជំរាបថាវត្តនៃប្រទេសនានា មានសង់អាគារដ៏ខ្ពស់ អាចមើលឃើញពីចម្ងាយ មានក្បាច់រចនា ទៅតាមស្ថាបត្យកម្មដ៏ប្រិមប្រិយ គួរឲ្យគយគន់ ។ ពេលល្ងាចបន្ទាប់ពីត្រឡប់ពីក្រុងកបិលពស្ដុវិញ យើងបានទៅថ្វាយបង្គំនមស្សការព្រះរតនត្រ័យ នៅកន្លែងព្រះអង្គប្រសូត ។

## ៤- ក្រុងកបិលពស្ដុ ( Kapilavastu )

ក្រុងកបិលពស្ដុ នៅក្នុងប្រទេសនេប៉ាល់ ជិតព្រំដែនប្រទេសឥណ្ឌា មានចម្ងាយប្រហែលម្ភៃគីឡូម៉ែត្រ ពីឧទ្យានលុម្ពិនី ។ ក្រុងកបិលពស្ដុជាកន្លែងដែលព្រះអង្គគង់នៅតាំងពីព្រះកុមារភាព រហូតដល់ព្រះអង្គទ្រង់យាងចេញទៅសាងព្រះផ្នួស ក្នុងព្រះជន្មម្ភៃប្រាំបួនព្រះវស្សា ។ សព្វថ្ងៃនេះ រមណីយដ្ឋាន កាលពីសម័យព្រះពុទ្ធដែលមានព្រះរាជវាំងប្រាសាទ ឥឡូវនេះប្រែក្លាយទៅជារហោស្ថាន នៅមានតែដុំឥដ្ឋ ដុំថ្ម មានកំពស់មិនលើសពីហាសិប សង់ទីម៉ែត្រ គួរឲ្យសង្វេគ ទឹកជា វត្ថុអ្វី ។ ក៏ដោយ ដែលស្ថិតនៅក្នុងលោកនេះ សុទ្ធតែមិនទៀង ។ បន្ទាប់ពីព្រះអង្គបានត្រាស់ដឹងមក ព្រះពុទ្ធអង្គ ព្រមទាំងព្រះភិក្ខុមួយពាន់ពីររយហាសិបអង្គ បាននិមន្ត ទៅក្រុងកបិលពស្ដុ ដើម្បីប្រោសព្រះបិតារបស់ព្រះអង្គ ព្រះនាមព្រះបាទព្រះសុទ្ធោទននិងព្រះរាជវង្សានុវង្ស។ ពួកយើងបានទៅមើលវត្ត និគ្រោធារាម ដែលសាងដោយព្រះញាតិព្រះអង្គ ។ បន្ទាប់ពីទស្សនាក្រុងកបិលពស្ដុហើយ ពួកយើងបានត្រឡប់មកឧទ្យានលុម្ពិនីវិញ ។



ព្រះរាជវាំងប្រាសាទ នៅមានតែដុំឥដ្ឋ

Le vestige du palai royal à Kapilavastu



វត្ត និគ្រោធារាម

Vestige de la pagode royale à Kapilavastu

46

## ៥ - ក្រុងកុសិនារា (Kushinagar)



ព្រះពុទ្ធអង្គទ្រង់បរិនិព្វាន

Le Bouddha entrait au Nirvana

គណាធម្មយាត្រាយើង បានចាកពីឧទ្យានលុម្ពិនី ឆ្ពោះទៅក្រុង
កុសិនារា ដែលជាកន្លែងព្រះពុទ្ធអង្គទ្រង់បរិនិព្វាន ។
នៅទីនោះពួកយើងបានឃើញ
កន្លែងថ្វាយព្រះភ្លើងព្រះសពនៃព្រះពុទ្ធអង្គ
ដែលបានរៀបពីឥដ្ឋដិនមានកម្ពស់ដូច
កូនភ្នំមួយតូច   មានព្រះពុទ្ធរូបទ្រង់យាងចូលព្រះនិព្វាន
ដាក់តម្កល់ក្នុង មហាមកុដពន្ធនចេតិយ
សម្រាប់ពុទ្ធបរិស័ទចូលទៅគោរពបូជា ។ ព្រះអង្គទ្រង់
យាងចូលនិព្វាននៅក្នុងឧទ្យានសាលវ័ន
ក្រោមដើមរាំងភ្នំទាំងគូ   មួយដុះចុងព្រះបាទ
មួយដុះនៅក្បែរព្រះកេស ។



កន្លែងថ្វាយព្រះភ្លើងព្រះសព

Lieu de l'incinération

ពាក្យបណ្តាំចុងក្រោយរបស់ព្រះពុទ្ធ ទៅដល់ព្រះភិក្ខុទាំង
ឡាយមានសេចក្តីថា: **"សង្ខារទាំងឡាយ មានកិរិយាអស់ទៅ**
**និងសាបសូន្យទៅជាធម្មតាអ្នករាល់គ្នាចូរញ៉ាំងប្រយោជន៍ឲ្យ**
**ដល់ព្រម ដោយមិនប្រមាទ"**
(គឺមិនធ្វេសប្រហែស ដូចជា          ការមិនបណ្តែតបណ្តោយក្នុងធម្មវិន័យជាដើម) ។
សូមជម្រាបថាពុទ្ធស្ថាននិមួយ ៗ សុទ្ធតែងមានកំពែងព័ទ្ធជុំវិញ មានម៉ោង ចេញចូល
ហើយមានឆ្មាំយាមល្បាតផង
។

## ៦ - ក្រុងវេសាលី (Vaishali)



ស្តូបនៅ ក្រុងវេសាលី



ស៊ីងជ័យជម្នះ នៅ ក្រុងវេ

មានចម្ងាយប្រហែលកៅសិប
គីឡូម៉ែត្រ ពីក្រុងកុសិនារា
ព្រះពុទ្ធអង្គ
ធ្លាប់គង់នៅទីនោះជាច្រើន
ព្រះវស្សា ។
ជាកន្លែងដែលព្រះអង្គទ្រង់យាងចេញទៅប្រោស
ព្រះបិតារបស់ព្រះអង្គ ព្រះនាមព្រះ**បាទសុទ្ធោទន** មុនពេលព្រះបាទសុទ្ធោទនទ្រង់យាង

ចូលទីព្រះវត្តត ជាកន្លែងដែលព្រះអង្គទ្រង់ដាក់ព្រះសង្ខារ បីខែមុនព្រះអង្គទ្រង់យាង
ចូលព្រះបរិនិព្វាន ។

**៧ - ស្រុកនាលន្ទា (Nalanda)**

យើងបានទៅមើលផ្ទះព្រះសារីបុត្រ ជាព្រះអគ្គសាវ័កស្តាំនៃព្រះពុទ្ធអង្គ ពួកយើងបានមើលមហាវិទ្យាល័យ ជាស្ថាប័នបរិយត្តិដ៏ធំ ផ្នែកព្រះវិន័យនិងព្រះធម្ម មានកំពែងថ្មនិងមានវិថីខ្វាត់ខ្វែងនាខាងក្នុង គួរឲ្យរមិលមើល ។



មហាវិទ្យាល័យ នៅ ស្រុកនាលន្ទា

**៨ - ក្រុងរាជគ្រឹះ (Rajgir)**

ភ្នំគិជ្ឈកូដ នមស្ការព្រះរតនត្រ័យ



យើងបាននាំគ្នាចូលទៅថ្វាយបង្គំព្រះរតនត្រ័យ នៅក្នុងវត្តវេឡុវ័ន (ព្រៃឫស្ស៊ី)
ហើយក៏បាននាំគ្នាឡើងភ្នំគិជ្ឈកូដ ។ ក្រុមធម្មយាត្រាយើងបានព្យាយាមឡើងតាមជណ្តើរស៊ីម៉ង់រហូតដល់កំពូលភ្នំ យើងឃើញនៅតាមជើងភ្នំមានដំណាក់ព្រះមោគ្គល្លាន ព្រះសារីបុត្រ ព្រះអានន្ទជាពិសេស នាកំពូលភ្នំ មាន ព្រះគន្ធកុដិនៃព្រះសម្មាសម្ពុទ្ធ ។ ព្រះពុទ្ធទ្រង់និមន្តចុះពាកគន្ធកុដិពីកំពូលភ្នំគិជ្ឈកូដ ដើម្បីទ្រង់បិណ្ឌបាត្រ តាមភូមិអ្នកស្រុក ។ ភិក្ខុទេវទត្តដែលត្រូវជាជីដូនមួយនៃព្រះសមណគោតម ជាព្រះញាតិវង្សខាងព្រះពុទ្ធមាតា ដោយការលោភលន់ច្រណែន បានប៉ុនប៉ងសម្លាប់ព្រះពុទ្ធអង្គ ដោយប្រើមធ្យោបាយ កលល្បិចផ្សេងៗ តែពុំដែលបានសម្រេចសោះឡើយ ។ ថ្ងៃមួយភិក្ខុទេវទត្ត បានប្រមៀលដុំថ្មមួយដុំធំពីលើភ្នំ តម្រង់ចំពុទ្ធអង្គ ដុំថ្មនោះក៏បែកជាដុំតូចៗហើយមានដុំថ្មមួយបានខ្ទាតមកត្រូវព្រះបាទព្រះអង្គបណ្តាលឲ្យចេញព្រះលោហិតនៅពេលនោះ ។ អំពើរបស់ភិក្ខុទេវទត្តនេះ ជា **អនន្តរិយកម្ម** គឺអំពើបាបដ៏ធ្ងន់ ឲ្យផលមិនចាំជាតិខាងមុខ ពោលគឺភិក្ខុទេវទត្តបានត្រូវព្រះធរណីស្រូប ក្នុងជាតិនេះ ។

__៩- ភ្នំផុងសិរិ__

យើងបានឡើងភ្នំផុងសិរិ ដែលជា កន្លែងព្រះពុទ្ធអង្គទ្រង់បានធ្វើ ទុក្ករកិរិយា រហូតដល់ព្រះរូបកាយនៃព្រះអង្គស្គាំងស្គម ឃើញតែព្រះតចោទិងព្រះអដ្ឋិ (ស្បែកនិងឆ្អឹង)។ សព្វថ្ងៃនេះនៅលើភ្នំនោះ មានវត្តព្រះសង្ឃជាតិទីបេ។

__១០- ពុទ្ធគយា__ (Bodh Gaya)



__ព្រះអង្គទ្រង់ទទួលនូវបាច់ស្បូវពីអ្នកគង្វាលគោ__

ជាកន្លែងដែលព្រះពុទ្ធអង្គបានត្រាស់ដឹង ចម្ងាយប្រហែលដប់គីឡូម៉ែត្រពីភ្នំផុងសិរិ តាមផ្លូវថ្មើរជើង ។ យើងបានដើរចាកពុទ្ធគយា កាត់តាម**ស្ទឹងនេរញ្ជរា**ដើម្បីមើលភូមិនាងសុជាតា ព្រះសមណគោតមព្រះអង្គទ្រង់ស្រង់ទឹកស្ទឹងនេរញ្ជរានេះ បន្ទាប់ពីព្រះពុទ្ធអង្គទ្រង់ឆាន់ នូវព្រះភត្តាហារនៃនាងសុជាតាហើយ ព្រះអង្គទ្រង់បាន **ទទួលនូវបាច់ស្បូវពីអ្នកគង្វាលគោ** ព្រះសិទ្ធត្ថគោតម ព្រះអង្គទ្រង់បានរៀបចំកន្លែងគង់ នៅក្រោមម្លប់នៃព្រះពោធិព្រឹក្ស ដោយព្រះអង្គទ្រង់បានតាំង**ព្រះអធិដ្ឋានយ៉ាងមុតមាំថា ដរាបណាព្រះអង្គមិនបានសម្រេចនូវការត្រាស់ដឹងព្រះអង្គ មិនចាកពីទីនេះឡើយ ។**

យើងបាននមស្សការ នៅក្រោមដើមព្រះពោធិព្រឹក្សត្រង់ កន្លែងត្រាស់ដឹងនៃព្រះពុទ្ធរហូតដល់ថ្ងៃលិច។ ព្រឹកឡើងក្រុមធម្មយាត្រាយើង បានថ្វាយ ខ្លួនជាឧបាសិកា ឧបាសក



__ដើមពោធិព្រឹក្ស កន្លែងព្រះអង្គត្រាស់ដឹង__



__ព្រះវិហារ មាន ដើមពោធិព្រឹក្សនៅពីក្រោយ__

នៅក្រោម ដើមពោធិព្រឹក្សនោះទៀត អ្នកខ្លះសមាទានសីលប្រាំ អ្នកខ្លះសមាទានសីលប្រាំបី តាមចិត្តសទ្ធាជ្រះថ្លារៀងៗខ្លួន ។

49

ពុទ្ធគយាមានភាព អ៊ូអរ ណែនណាន់តាន់តាប់ ដោយមានជនជាតិ
នានាជាច្រើនបានចូលមក គោរពបូជានៅទី



ព្រះពុទ្ធរូប ក្នុង
ព្រះវិហារ នៅពុទ្ធគយា



ស្រះមុចលិន្ទ នៅពុទ្ធគយា

នោះ  ហើយថែមទាំងមានផ្ទះ លក់វត្ថុអនុស្សាវរីយ៍ជាច្រើន ដូចជា រូបចម្លាក់និងសៀវភៅធម៌ជាដើម ។

**១១ - ក្រុងពារាណសី (Varanasi)**

បន្ទាប់ពីពុទ្ធគយាមក ក្រុមធម្មយាត្រាយើងបានមកដល់ក្រុង ពារាណសី ដែលមានទន្លេគង្គាហូរកាត់។ ព្រះសមណគោតម ទ្រង់បានសម្តែង បឋមទេសនា ដើម្បីប្រោស បញ្ចវគ្គីយ៍ គឺជាតាបសទាំងប្រាំរូប ដែលធ្លាប់ដើរដង្ហែតាមព្រះអង្គ



ស្តូប កំពស់សែសិបពីរម៉ែត្រនិងប្រាំមួយសង់ទីម៉ែត្រ

នៅពេលដែលព្រះអង្គកំពុងស្វែងរកធម៌នៅឡើយ ។ តែដល់ក្រោយមក បន្ទាប់ពីព្រះអង្គទ្រង់ឈប់ធ្វើទុក្ករកិរិយា ដោយព្រះអង្គបានជ្រើសយកផ្លូវកណ្តាលវិញ  តាបសទាំងប្រាំរូបនោះបែកគំនិតឈប់ដើរតាមព្រះអង្គតទៅទៀត។ សព្វថ្ងៃនេះមានស្តូបមួយ កំពស់សែសិបពីរម៉ែត្រនិងប្រាំមួយសង់ទីម៉ែត្រដែលព្រះបាទធម្មាសោកទ្រង់បានសាងគោរពបូជាដល់ព្រះបរមគ្រូនៃយើង។ ធម្មយាត្រាយើងក៏បានទៅនមស្សការ នៅទីនោះ ហើយជាមួយគ្នានោះក៏មានពុទ្ធបរិស័ទប្រទេសឯទៀតដើរប្រទក្សិណព្រះស្តូបនោះដែរ ។

## ១២ - សង្កស្ស



បន្ទាប់ពីព្រះសិទ្ធត្ថទ្រង់បានព្រះជន្មប្រាំពីរថ្ងៃ ព្រះមាតាព្រះអង្គ ព្រះនាង**សិរិមហាមាយា** បានយាងចូលព្រះទីវង្គត។ បន្ទាប់ពីព្រះអង្គបានត្រាស់ដឹង ព្រះសម្ពុទ្ធ ទ្រង់បាននិមន្តទៅប្រោសព្រះមាតានៅឯឋានតាវត្តឹង្ស។ សង្កស្ស ជាកន្លែងដែល ព្រះពុទ្ធអង្គទ្រង់យាងចុះពីឋានតាវត្តឹង្សវិញ។ ក្រុមយើងក៏បានទៅគោរពបូជាកន្លែងនោះដែរ។

## ១៣ - ក្រុងដែល្លីជាលើកទីពីរ

ជាចុងក្រោយនៃធម្មយាត្រា យើងត្រឡប់មកក្រុងដែល្លីជាលើកទីពីរ ដើម្បីឡើងយន្តហោះត្រឡប់មកប្រទេសបារាំងវិញ។ យើងស្នាក់នៅក្រុងដែល្លីពីរយប់បីថ្ងៃ បានទៅទស្សនា វិមានផ្កាឈូកជារមណីយដ្ឋាន សង់សម្រាប់ប្រជាជនទូទៅ មិនរើសអើងថាសាសនាណាឡើយ បានទៅធ្វើសមាធិនៅសតិបដ្ឋានសូត្រ



វិមានផ្កាឈូក



សតិបដ្ឋានសូត្រ

ដែលជាកន្លែងព្រះអង្គទ្រង់បានបង្រៀន ធម៌សតិបដ្ឋាន យើងបានដើរទៅផ្សារ មើលក្រុងជិះរទេះភ្លើងក្នុងដី និងទិញវត្ថុផ្សេងៗជាអនុស្សាវរីយ៍។ក្រុមយើងបានត្រឡប់មកដល់ក្រុងប៉ារីសវិញ ដោយសុវត្ថិភាពទាំងអស់គ្នា ។

51

__សេចក្តីសន្និដ្ឋាន__



ក្នុងពុទ្ធស្ថានទាំងបួន មានតែពុទ្ធស្ថាននៅ ឯពុទ្ធគយាទេ ដែលមានមនុស្សអ៊ូអរដ៏ច្រើនទាំងយប់ទាំងថ្ងៃ មានសណ្ឋាគារនិងភោជនីយដ្ឋាន ។ ឯក្រុងដទៃទៀត ធម្មយាត្រាយើង ច្រើនតែស្នាក់នៅតាមវត្ត ដូចជាវត្តជាតិភូមា វត្តសិរី លង្កាជាដើម។ ចំពោះវត្តខ្មែរយើងវិញ មានតែបីកន្លែងទេ គឺនៅលុម្ពិនី ញូវដែល្ហី និងសាវត្ថី ។ សព្វថ្ងៃនេះព្រះសង្ឃជាតិខ្មែរ គង់នៅប្រទេសឥណ្ឌាកំពុងតែអំពាវនាវ ដល់ស្រទាប់ប្រជាជនឲ្យជួយកសាងវត្តឯពុទ្ធគយា ដែលបានជាវដីបានខ្វះហើយ ។ នា ពារាណសីពុំទាន់មានមធ្យោបាយគ្រប់គ្រាន់នឹងជាវដីផង។ ព្រះសង្ឃខ្មែរគង់នៅប្រទេសឥណ្ឌា គឺដើម្បីបន្តវិជ្ជាខាងពុទ្ធសាសនា បន្ទាប់ពីចប់មធ្យមសិក្សានៅពុទ្ធិកវិទ្យាល័យ នៃព្រះរាជាណាចក្រកម្ពុជា។ ដោយវត្តពុទ្ធសាសនា មានតិច នៅក្នុងប្រទេសឥណ្ឌា ព្រះសង្ឃខ្មែរដែលត្រូវបន្ត វិជ្ជាពុទ្ធសាសនា នៅប្រទេសនេះ មានការលំបាក ដោយភាគច្រើន និមន្តមកតាមមធ្យោបាយផ្ទាល់ខ្លួន គឺគ្មានអាហារូបករណ៍ឡើយ ។ សមណនិស្សិតទាំងនោះ សុទ្ធតែដោះស្រាយផ្ទាល់គ្មានទាយកទាយិកាណាប្រគេនបិណ្ឌបាតឡើយ គួរខ្មែរយើងនៅបរទេស ជួយឧបត្ថម្ភដល់សមណនិស្សិតទាំងនោះផង ។

(ចប់ដោយសង្ខេបតែប៉ុណ្ណេះ)

52